ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
## លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងកម្មវិធី លៀងសាយភោជនប្រចាំឆ្នាំ ២០២៤

ថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

សណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤

- **លោក រ័ត្ន សោភ័ណ ប្រធានសមាគមធនាគារនៅកម្ពុជា**
- **លោកជំទាវ ឌិត នីតា ប្រធានក្រុមប្រឹក្សាភិបាល សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុងកម្មវិធីលៀងសាយភោជនប្រចាំឆ្នាំ២០២៤ នៃមហាគ្រួសារវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ ការជួបជុំរបស់យើងនាពេលនេះ មិនមែនគ្រាន់តែជាឱកាសសម្រាប់គណៈគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានជួបប្រាស្រ័យទាក់ទងគ្នាដើម្បីបង្កើនកិច្ចសហប្រតិបត្តិការប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាឱកាសពង្រឹងចំណងសាមគ្គីភាពនិងភាតរភាពរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាមួយនឹងអាជ្ញាធរត្រួតពិនិត្យផងដែរ។ លើសពីនេះ នេះជាឱកាសមួយដែលយើងអាចធ្វើការឆ្លុះបញ្ចាំងនិងពិនិត្យមើលលើវឌ្ឍនភាពដែលវិស័យធនាគារនិងហិរញ្ញវត្ថុសម្រេចបាននាពេលកន្លងមក និងកំណត់បញ្ហាថ្មីៗដែលយើងកំពុងប្រឈម ព្រមទាំងដាក់ទិសដៅរួមគ្នាដោះស្រាយបញ្ហា ដើម្បីកសាងប្រព័ន្ធធនាគាររបស់យើងឱ្យមានភាពរឹងមាំនិងរីកចម្រើនបន្ថែមទៀត។

ឆ្នាំនេះក៏ដូចជាឆ្នាំមុនៗដែរ ប្រព័ន្ធធនាគាររបស់យើងនៅបន្តរក្សាបានស្ថិរភាព ប៉ុន្តែប្រឈមនឹងបញ្ហាចម្បងៗមួយចំនួនដូចជា កំណើនយឺតនៃឥណទាន ការកើនឡើងនៃឥណទានមិនដំណើរការ ការកើនឡើងថ្លៃដើមមូលធន និងការថយចុះនៃលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាដើម។ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល សម្ពាធអតិផរណា ការរំខានដល់ខ្សែច្រវាក់ផ្គត់ផ្គង់ និងភាពតានតឹងភូមិសាស្ត្រនយោបាយ បានធ្វើឱ្យស្ថានភាពទីផ្សារហិរញ្ញវត្ថុមានការប្រែប្រួល និងបានជះឥទ្ធិពលដល់អត្រាការប្រាក់ទីផ្សារ ដែល


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការណ៍នេះបានដាក់សម្ពាធដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា បើនិយាយជារួម និងដល់ប្រជាជនកម្ពុជាមួយចំនួន បើនិយាយដោយឡែក។ ស្របពេលជាមួយគ្នានេះ ការកើនឡើងនៃសកម្មភាពធនាគារស្រមោល ការឆបោកតាមអនឡាញ (online scam) និងការកើនឡើងនៃឧក្រិដ្ឋកម្មសាយប័រកំពុងតែបង្កហានិភ័យដល់ប្រព័ន្ធធនាគារ ដែលទាមទារឱ្យយើងត្រូវបង្កើនការប្រុងប្រយ័ត្ន ជាពិសេស ការការពារផលប្រយោជន៍របស់អតិថិជនក្នុងប្រព័ន្ធធនាគារពីការខាតបង់នានា ជាយថាហេតុ។

ទោះបីជាប្រឈមនឹងបញ្ហាមួយចំនួនក៏ដោយ ប្រព័ន្ធធនាគារនៅកម្ពុជាបន្តដើរតួនាទីជាអន្តរការីហិរញ្ញវត្ថុប្រកបដោយទំនុកចិត្ត។ វឌ្ឍនភាពនេះសម្រេចបានដោយឆ្លុះបញ្ចាំងតាមរយៈជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគិនទាំងក្នុងនិងក្រៅស្រុក ចំពោះវិស័យធនាគារក៏ដូចជាស្ថិរភាពនិងនិរន្តរភាពនៃសេដ្ឋកិច្ចកម្ពុជា ដែលជ្រកក្រោមម្លប់សន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងអាណត្តិកន្លងទៅ និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងអាណត្តិទី៧នេះ។

ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជានឹងបន្តរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិស្របតាមនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តនិងពង្រឹងវិធានការនានាដែលផ្តោតលើការរក្សាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការពង្រឹងភាពធន់របស់ប្រព័ន្ធធនាគារ ព្រមទាំងអនុវត្តកិច្ចការជាច្រើនទៀតដែលរួមមាន៖ ១/-បង្កើនប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុ ២/-លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ៣/-ពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្អែកលើហានិភ័យ ៤/-ជំរុញបរិយាបន្នហិរញ្ញវត្ថុ ៥/-ពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ៦/-ការពារអតិថិជន ៧/-ធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ៨/-រៀបចំយន្តការការពារប្រាក់បញ្ញើ ៩/-ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង ១០/-បន្តអភិវឌ្ឍសមត្ថភាពធនធានមនុស្សឱ្យស្របតាមការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តថែរក្សានិងធ្វើឱ្យកាន់តែប្រសើរឡើងនូវសមិទ្ធផលនានា ដែលបានកើតឡើងពីកិច្ចខិតខំប្រឹងប្រែង និងការរួមចំណែករបស់ **ឯកឧត្តម ជា ចាន់តូ អតីតទេសាភិបាល និងទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា** ក្នុងការអភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធធនាគារឱ្យមានការរីកចម្រើននិងមានស្ថិរភាពរហូតដល់សព្វថ្ងៃនេះ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

ក្នុងស្ថានភាពដែលសេដ្ឋកិច្ចកម្ពុជាកំពុងត្រូវបានស្តារឡើងវិញ និងដើម្បីជួយសម្រាលបន្ទុករបស់អតិថិជនដែលកំពុងជួបប្រទះបញ្ហាហិរញ្ញវត្ថុ ក៏ដូចជាជួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាបាននូវសន្ទនីយភាពគ្រប់គ្រាន់ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការថ្មីៗ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចជា៖ ១/-អនុញ្ញាតឱ្យបន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិន ត្រឹមកម្រិត ១,២៥% រហូតដល់ចុងឆ្នាំ២០២៥ ២/-អនុញ្ញាតឱ្យអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយវត្ថុ និងរូបិយប័ណ្ណត្រឹមកម្រិត ៧% រហូតដល់ចុងឆ្នាំ២០២៥ និង ៣/-អនុញ្ញាតឱ្យរៀបចំឥណទានឡើងវិញជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ។

ធនាគារជាតិនៃកម្ពុជា សូមលើកទឹកចិត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចូលរួមសហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយចីរភាព តាមរយៈការគោរពតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានាជាធរមាន។ ស្របពេលដែលប្រព័ន្ធធនាគារជាចន្ទល់ដ៏សំខាន់ក្នុងការទ្រទ្រង់ខឿនសេដ្ឋកិច្ចជាតិ យើងត្រូវសម្លឹងឆ្ពោះទៅមុខ និងត្រូវសម្របខ្លួននិងដោះស្រាយបញ្ហាប្រឈមនានា ដើម្បីបន្តជំរុញកំណើនសេដ្ឋកិច្ច និងរក្សាទំនុកចិត្តរបស់សាធារណជននិងវិនិយោគិនមកលើប្រព័ន្ធធនាគារ។ ក្នុងន័យនេះ ខ្ញុំសូមផ្តល់ជូននូវគោលការណ៍ណែនាំមួយចំនួន ដែលខ្ញុំជឿថាមានសារៈសំខាន់សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីទទួលបានជោគជ័យ៖

**ទី១៖ ការកសាង និងពង្រឹងសមត្ថភាព**

ក្នុងបរិការណ៍ដែលពិភពលោកមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដែលមិនធ្លាប់មានពីមុនមក គ្រឹះស្ថានគួរតែបន្តខិតខំពង្រឹងសមត្ថភាពស្ថាប័នខ្លួន តាមរយៈការកសាងធនធានមនុស្ស ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរឹងមាំ ជាពិសេស ការពង្រឹងការធ្វើបរិវត្តកម្មឌីជីថល (digital transformation) និងនវានុវត្តន៍បច្ចេកវិទ្យា (technological innovation) ជាដើម។

**ទី២៖ ការចាប់យកហិរញ្ញវត្ថុប្រកបដោយចីរភាព**

កត្តាបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) លែងជាពាក្យសម្រាប់អនាគត ឬជាពាក្យចចាមអារ៉ាមតទៀតហើយ ដោយបច្ចុប្បន្ននេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើរតួនាទីជាអ្នកដឹកនាំក្នុងការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព។ ដូចនេះ ខ្ញុំសូមលើកទឹកចិត្តដល់គ្រឹះស្ថានទាំងអស់ផ្តល់សេវា និងបង្កើតផលិតផលឬសេវាថ្មីៗ ដោយគិតគូរលើគោលការណ៍ចីរភាព ជាពិសេស

ផលិតផលឬសេវាដែលផ្តោតលើការជួយបរិស្ថានបៃតង ស្របតាមគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា ។

**ទី៣៖ ការគ្រប់គ្រងហានិភ័យ និងសុវត្ថិភាពសាយប័រ**

ជាមួយនឹងឱកាសថ្មី ហានិភ័យថ្មីៗក៏មកដល់ ជាពិសេសសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណែត ស្របពេលដែលហានិភ័យប្រតិបត្តិការ និងភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុបានក្លាយជាកង្វល់ដល់ស្ថាប័នហិរញ្ញវត្ថុ។ ក្នុងន័យនេះ ខ្ញុំសូមជំរុញគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តពង្រឹងសមត្ថភាពគ្រប់គ្រង ដើម្បីទប់ស្កាត់និងការពារការគំរាមកំហែងនៃការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណែត ការក្លែងបន្លំ និងការប៉ះទង្គិចជាប្រព័ន្ធ ដែលអាចប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់គ្រឹះស្ថានផ្ទាល់ក៏ដូចជាអតិថិជនផងដែរ។

**ទី៤៖ ការអនុលោមតាមបទប្បញ្ញត្តិ និងតម្លាភាព**

កន្លងមក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានខិតខំអនុវត្តតាមបទប្បញ្ញត្តិបានយ៉ាងល្អ ដែលខ្ញុំសូមឆ្លៀតឱកាសនេះ កោតសរសើរ និងសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិនានា ដែលដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ ខ្ញុំស្នើឱ្យគ្រឹះស្ថានទាំងអស់បន្តប្រកាន់ភ្ជាប់នូវគោលការណ៍អនុលោមភាពតាមបទប្បញ្ញត្តិផ្សេងៗទៀត និងធានាឱ្យបាននូវតម្លាភាពខ្ពស់ ដើម្បីពង្រឹងកេរ្តិ៍ឈ្មោះ និងទំនុកចិត្តរបស់អតិថិជនមកលើប្រព័ន្ធធនាគារ។

**ទី៥៖ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងសាធារណៈ**

ក្នុងស្ថានភាពដែលសេដ្ឋកិច្ចកម្ពុជាកំពុងបន្តងើបឡើងវិញ ដោយប្រឈមនឹងភាពមិនប្រាកដប្រជា ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងគ្រឹះស្ថាននិងគ្រឹះស្ថាន និងរវាងគ្រឹះស្ថាននិងអាជ្ញាធរ មានសារៈសំខាន់ណាស់។ លើសពីនេះ ទំនាក់ទំនងជាមួយសាធារណជននិងស្ថាប័នពាក់ព័ន្ធក៏មានភាពចាំបាច់ផងដែរ ពីព្រោះទំនាក់ទំនងល្អនឹងបង្កើនតម្លាភាពនិងភាពទុកចិត្តមកលើប្រព័ន្ធធនាគារ។ ក្នុងន័យនេះ យើងត្រូវយកចិត្តទុកដាក់ទៅលើការបកស្រាយ និងការពន្យល់ពីគោលនយោបាយ ឬវិធានការនានាដល់អតិថិជន និងមហាជនឱ្យបានច្បាស់លាស់ ជាពិសេសឆ្លើយតបទៅនឹងការបំភ្លៃព័ត៌មាននានា ដើម្បីទប់ស្កាត់នូវចលាចល និងការបំពុលបរិយាកាសសង្គម ជាដើម និង

**ទី៦៖ ការពង្រឹងកិច្ចការពារអតិថិជន**

ស្របពេលដែលប្រព័ន្ធធនាគារមានការរីកចម្រើនជាលំដាប់ ផលិតផលហិរញ្ញវត្ថុថ្មីៗត្រូវបានបង្កើតឡើងដោយភ្ជាប់មកជាមួយនូវលក្ខខណ្ឌច្រើន និងមានភាពស្មុគស្មាញជាងមុន។ ការណ៍នេះអាចបង្កឱ្យមានការភាន់ច្រឡំដល់អតិថិជន ដែលទាមទារឱ្យគ្រឹះស្ថានត្រូវកំណត់លក្ខខណ្ឌឱ្យបាន

ច្បាស់លាស់ មានតម្លាភាព និងពន្យល់ផលិតផលនោះឱ្យបានច្បាស់ ក្នុងគោលដៅលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុ ពង្រឹងជំនឿទុកចិត្តរយៈពេលវែងនៅក្នុងប្រព័ន្ធធនាគារ និងកិច្ចការពារអតិថិជនជាដើម។ ការផ្តល់កម្ចីប្រកបដោយការទទួលខុសត្រូវមិនត្រឹមតែកាត់បន្ថយហានិភ័យនៃការខកខាន និងការលំបាកផ្នែកហិរញ្ញវត្ថុតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយរក្សាទីផ្សារឥណទានឱ្យមានសុខភាពល្អតាមរយៈការលើកទឹកចិត្តអ្នកខ្ចីឱ្យបង្កើតទម្លាប់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។ ក្នុងន័យនេះ ខ្ញុំសូមស្នើឱ្យគ្រឹះស្ថានធ្វើការវាយតម្លៃសមត្ថភាពរបស់អ្នកខ្ចីប្រាក់ឱ្យបានហ្មត់ចត់ និងផ្តល់នូវលក្ខខណ្ឌប្រកបដោយតម្លាភាពនិងយុត្តិធម៌ ដើម្បីជៀសវាងការផ្តល់កម្ចីជាន់គ្នាឬកម្ចីដែលហួសសមត្ថភាពសងរបស់អតិថិជន ដែលអាចឈានដល់បំណុលលើសលប់។

មុននឹងបញ្ចប់ ខ្ញុំសូមសម្តែងនូវការគោរពសម្តែងនូវកតញ្ញូ កតវេទិតា យ៉ាងជ្រាលជ្រៅជាទីបំផុត និងចងចាំជានិច្ច ចំពោះគុណូបការៈ និងស្នាដៃមិនអាចកាត់ថ្លៃបានរបស់ **ឯកឧត្តម ជា ចាន់តូ អតីតទេសាភិបាល និងទេសាភិបាលកិត្តិយស** នៃធនាគារជាតិនៃកម្ពុជា ក្នុងការកែទម្រង់ និងការផ្លាស់ប្តូរវិស័យហិរញ្ញវត្ថុរបស់កម្ពុជា។ ភាពជាអ្នកដឹកនាំ ចក្ខុវិស័យ និងការខិតខំប្រឹងប្រែងធ្វើពលិកម្មគ្រប់បែបយ៉ាងទាំងកម្លាំងកាយ ប្រាជ្ញា ស្មារតី បានរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងវិស័យហិរញ្ញវត្ថុនៅកម្ពុជា ឱ្យក្លាយជាប្រព័ន្ធហិរញ្ញវត្ថុដ៏រស់រវើក និងទំនើប ដូចដែលយើងទាំងអស់គ្នាបានឃើញសព្វថ្ងៃនេះ។ កត្តានេះគឺផ្នែកមួយនៃការរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចរបស់យើង។

ការដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងឆ្នាំ១៩៩៩ គឺជាសមិទ្ធផលដ៏សំខាន់មួយសម្រាប់ប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ។ ការសម្រេចចិត្តរបស់ **ឯកឧត្តម ជា ចាន់តូ អតីតទេសាភិបាល** ក្នុងការរៀបចំកំណែទម្រង់នៃប្រព័ន្ធធនាគារដោយការបង្កើនដើមទុនអប្បបរមា និងការសម្រេចចិត្តបិទធនាគារពាណិជ្ជចំនួន១៧ គឺជារបត់មួយដ៏សំខាន់ក្នុងការកសាងវិស័យហិរញ្ញវត្ថុមួយឱ្យមានភាពរឹងមាំនិងធន់ជាងមុន។ ម្យ៉ាងទៀត ការបង្កើតមុខងារត្រួតពិនិត្យ និងបទប្បញ្ញត្តិដ៏រឹងមាំនៅក្នុងធនាគារជាតិនៃកម្ពុជា បានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រព័ន្ធធនាគារ ឱ្យទៅជាសសរស្តម្ភដ៏រឹងមាំសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។

លើសពីនេះ ការប្តេជ្ញាចិត្តរបស់លោកក្នុងការកសាងធនធានមនុស្សក្នុងវិស័យហិរញ្ញវត្ថុតាមរយៈការពង្រីកនិងការពង្រឹងមូលធនមនុស្សរបស់ប្រទេសជាតិ គឺជាសក្ខីភាពដ៏ជាក់ស្តែងនៃភាពជាអ្នកដឹកនាំ និងការលះបង់ដ៏មោះមុត។ ចក្ខុវិស័យរបស់ លោក ក្នុងការបង្កើតប្រព័ន្ធហិរញ្ញវត្ថុដែលស្របតាមស្តង់ដា និងឧត្តមានុវត្តអន្តរជាតិ បានបន្សល់ទុកនូវកេរ្តិ៍ដំណែលដែលមិនអាចកាត់ថ្លៃបាន ដែលថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកនៃធនាគារនៃកម្ពុជា ក៏ដូចជាវិស័យហិរញ្ញវត្ថុទាំងមូលនឹងបន្តថែរក្សាឱ្យបិតបេរជានិរន្តរ៍។

នៅក្នុងរាត្រីជប់លៀងដែលនឹងត្រូវចាក់បញ្ចាំងនាពេលបន្តិចទៀតនេះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ នឹងបានឃើញដោយផ្ទាល់អំពីភាពជាអ្នកដឹកនាំដ៏ប៉ិនប្រសប់របស់ ឯកឧត្តម ជា ចាន់តូ ក្នុងវិស័យធនាគារ។ សូមអញ្ជើញទស្សនាវីដេអូដែលឆ្លុះបញ្ចាំងពីកេរ្តិ៍ដំណែលដ៏អស្ចារ្យរបស់លោកនាពេលបន្តិចទៀតនេះ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលការងារដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រេចបានកន្លងមក។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលបានរៀបចំកម្មវិធីលៀងសាយភោជនប្រចាំឆ្នាំនេះ ប្រកបដោយពិលាស និងសូមប្រសិទ្ធពរជ័យជូនចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ទាំងអស់ សូមជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**